សេចក្តីប្រកាសសារព័ត៌មានរួម

សម្រាប់ចេញផ្សាយបន្ទាន់

# វិធានការអតិរក្សបន្ទាន់ចាំបាច់ដើម្បីការពារប្រភេទសត្វក្រចកជើងចំពាម ដែលមានចំនួនធ្លាក់ចុះគួរឱ្យបារម្ភក្នុងអំឡុងមួយទសវត្សរ៍ចុងក្រោយនេះ

ថ្វីបើក្រសួងបរិស្ថាន  អង្គការ WWF ព្រមទាំងដៃគូទាំងអស់ បានបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងកាអនុវត្តច្បាប់យ៉ាងខ្លាំងក្លាយ៉ាងណាក៏ដោយ របាយការណ៍មួយដែលចេញផ្សាយរួមគ្នាដោយក្រសួងបរិស្ថាន និងអង្គការ WWF ស្តីពីស្ថានភាពនៃប្រភេទសត្វក្រចកជើងចំពាម បានបង្ហាញថា ចំនួនសត្វក្រចកជើងចំពាម ក្នុងដែនជម្រកសត្វព្រៃស្រែពក និងភ្នំព្រេចបានធ្លាក់ចុះក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ហើយបានបង្ហាញនូវភាពចាំចាច់ក្នុងការដាក់ចេញនូវវិធានការថ្មីនិងប្រកបដោយភាពច្នៃប្រឌិតជាងមុនជាបន្ទាន់ ដើម្បីទប់ស្កាត់ស្ថានភាពធ្លាក់ចុះនេះ។

លទ្ធផលនៃការតាមដានសត្វក្រចកជើងចំពាមក្នុងចន្លោះឆ្នាំ ២០១០-២០២០ នៅក្នុងដែនជម្រកទាំងពីរបានបង្ហាញថា ចំនួនសត្វទន្សោងបានធ្លាក់ចុះប្រមាណ ៧២% សត្វឈ្លូសប្រមាណ ៥២%  និងសត្វជ្រូកព្រៃប្រមាណ ១៨% បើប្រៀបធៀបនឹងលទ្ធផលនៃការស្រាវជ្រាវនៅឆ្នាំ ២០១០-២០១១។

របាយការណ៍ដដែលនេះក៏បានបង្ហាញដែរថាចំនួនសត្វរមាំង ខ្ទីង និងប្រើស មានកម្រិតតិចតួចហើយនៅរាយប៉ាយដាច់ដោយឡែកពីគ្នានៅក្នុងតំបន់ទាំងពីរនេះ។

**ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋលេខាធិការ និងអ្នកនាំពាក្យក្រសួងបរិស្ថានមានប្រសាសន៍ថា៖ "ការធ្លាក់ចុះនេះជាការក្រើនរំលឹកដល់យើងទាំងអស់គ្នា ប៉ុន្តែវាក៏ផ្តល់ជាឱកាសឱ្យយើងទាំងអស់គ្នាក្នុងការខិតខំបន្ថែមទៀត ដើម្បីទប់ស្កាត់និន្នាការនៃការធ្លាក់ចុះនេះ។ ឯកឧត្តមបានបន្តទៀតថាស្ថានភាពនសការធ្លាក់ចុះអាចនឹងធ្ងន់ធ្ងរជាងនេះ ប្រសិនបើគ្មានការពង្រឹងការអនុវត្តច្បាប់និងការគ្រប់គ្រងតំបន់ការពារយ៉ាងមឹងម៉ាត់នោះទេពីការខិតខំដោយមិនខ្លាចនឿយហាត់ដោយមន្ត្រីឧទ្យានុរក្សរបស់មន្ទីរបរិស្ថានខេត្តក្រសួងបរិស្ថាន ក្រុមល្បាតសហគមន៍ អាជ្ញាធរមូលដ្ឋាន និងបុគ្គលិកអង្គការ WWF ក្នុងការដើរល្បាត និងពង្រឹងការអនុវត្តច្បាប់ទាំងក្នុងនិងក្រៅតំបន់ការពារទាំងពីរ។

**ឯកឧត្តម នេត្រ ភក្ត្រា** បានពិពណ៌នាបន្តទទៀតថា បើទោះជាមានការធ្លាក់ចុះនូវពពួកសត្វក្រចកជើងចំពាមនៅក្នុងដែនជម្រកស្រែពក និងភ្នំព្រេច ចំនួនប្រភេទសត្វក្រចកជើងចំពាមមួយចំនួនបានកើនឡើង ឬស្ថិតក្នុងកម្រិតថេរនៅក្នុងដែនជម្រកសត្វព្រៃមួយចំនួនផ្សេងទៀត។

ស្ថានភាពដ៏អាក្រក់នេះមិនបានកើតឡើងតែក្នុងប្រទេសកម្ពុជានោះទេ ដោយសារតែចំនួនសត្វព្រៃនៅលើសកលលោក ទាំងសត្វរស់នៅលើដីនិងក្នុងទឹក ក៏បានធ្លាក់ចុះខ្លាំងបំផុត ដល់ ៦៨% ជាមធ្យម ក្នុងរយៈពេល ៥០ ឆ្នាំចុងក្រោយនេះ បើគិតចាប់តាំងពីឆ្នាំ១៩៧០ មក។

ការបរបាញ់ខុសច្បាប់ចាប់តាំងពីអតីតកាលមកដល់ពេលបច្ចុប្បន្ន បូកផ្សំនិងវិបត្តិអន្ទាក់ ដែលជម្រុញដោយការជួញដូរសត្វព្រៃខុសច្បាប់ សុទ្ធសឹងជាមូលហេតុចម្បងដែលបណ្ដាលឱ្យសត្វក្រចកជើងចំពាមនៅដែនជម្រកសត្វព្រៃស្រែពក និងភ្នំព្រេចធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ។

**កញ្ញា** Milou Groenenberg ប្រធានផ្នែកស្រាវជ្រាវ និងតាមដានជីវៈចម្រុះនៃអង្គការ WWF បាននិយាយថាអន្ទាក់គឺជាកត្តាគម្រាមកំហែងដ៏ចម្បងមួយចំពោះសត្វក្រចកជើងចំពាមនៅក្នុងដែនជម្រកទាំងពីរ ហើយក៏ជាមូលហេតុដែលធ្វើឱ្យចំនួនសត្វខ្លារខិនដែលជាប្រភេទស៊ីសាច់សត្វក្រចកជើងចំពាមទាំងនេះជាអាហារ ធ្លាក់ចុះដែរ។"

បើទោះជារបាយការណ៍បានបង្ហាញពីស្ថានភាពធ្លាក់ចុះដ៏គួរឱ្យបារម្ភនេះក៏ដោយ ក្ដីសង្ឃឹមនៅតែមាននៅឡើយក្នុងការជួយសង្គ្រោះសត្វព្រៃទាំងនេះពីការផុតពូជ។ ប៉ុន្តែប្រសិនបើគ្មានវិធានការអភិរក្សបន្ទាន់និងប្រកបដោយភាពច្នៃប្រឌិតថ្មីទេ ដើម្បីទប់ស្កាត់កត្តាគម្រាមកំហែងចម្បងៗទាំងនេះទេ ជីវៈចម្រុះនឹងនៅតែបន្តធ្លាក់ចុះបន្តិចម្តងៗ រហូតដល់អាចបាត់បង់ទាំងស្រុងតែម្តង។

**លោក សេខ ទៀក** នាយកអង្គការ WWF មានប្រសាសន៍ថា វាមិនទាន់យឺតពេលនៅឡើយទេក្នុងការកែប្រែស្ថានភាពនេះ ប៉ុន្តែវាតម្រូវឱ្យពួកយើងធ្វើសកម្មភាពអភិរក្សរួមគ្នាជាបន្ទាន់ឥឡូវនេះដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

លោកមានប្រសាសន៍ថា៖ "គំហើញរបស់អ្នកវិទ្យាសាស្ត្រនៅក្នុងរបាយការណ៍នេះ បានបង្ហាញឲ្យឃើញនូវតម្រូវការនៃដំណោះស្រាយបន្ទាន់ និងថ្មីៗ ដើម្បីកែប្រែនូវអត្រានៃការធ្លាក់ចុះនេះ ខណៈពេលដែលកំពុងស្វែងរកការគ្រប់គ្រង ការប្រើប្រាស់ និងការបែងចែកធនធានធម្មជាតិឲ្យបានប្រសើរជាងនេះ"។

ក្រសួងបរិស្ថាន និងអង្គការ WWF បានធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍មូលដ្ឋាន និងដៃគូនានា ដើម្បីរៀបចំឡើងនូវវិធានការអភិរក្សខ្លាំងក្លាជាងមុន ដើម្បីកាត់បន្ថយការបរបាញ់ខុសច្បាប់ និងពង្រឹងការអនុវត្តច្បាប់។ ក្រសួងបរិស្ថាន និងអង្គការ WWF កំពុងសិក្សាពីលទ្ធភាពក្នុងការអនុវត្តកម្មវិធីស្តារសត្វក្រចកជើងចំពាមឡើងវិញ ដែលជាតម្រូវការបន្ទាន់ក្នុងការបញ្ឈប់និន្នាការធ្លាក់ចុះនៃចំនួនសត្វទាំងនេះ និងចាត់វិធានការឆ្លើយតបទៅដល់ឫសគល់នៃការជួញដូរសត្វព្រៃខុសច្បាប់។

ក្រោមជំនួយឧបត្ថម្ភថវិកាពីទីភ្នាក់ងារជំនួយអាមេរិក (USAID) សហភាពអឺរ៉ុប (EU) រដ្ឋាភិបាលអាល្លឺម៉ង់ (BMZ) រដ្ឋាភិបាលប៊ែលហ្សិក (DGD) កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UN Environement) GEF រដ្ឋាភិបាលស៊ុយអែត (Sida) IKEA Welthungerhilfe (WHH) Humanscale និងបណ្តាញអង្គការ WWF (WWF-អាមេរិក WWF-ប៊ែលហ្សិក WWF-អាល្លឺម៉ង WWF-ស៊ុយអែត និង WWF-ស្វីស) ការគ្រប់គ្រងតំបន់ការពារធម្មជាតិនៅក្នុងដែនជម្រកសត្វព្រៃស្រែពក និងភ្នំព្រេច ផ្តោតទៅលើការស្រាវជ្រាវនិងតាមដានជីវៈចម្រុះ ការកសាងសមត្ថភាពសម្រាប់

ការអនុវត្តច្បាប់ ការប្រយុទ្ធប្រឆាំងនឹងការបរបាញ់ខុសច្បាប់ ការជួញដូរសត្វព្រៃខុសច្បាប់ ការកាប់ឈើខុសច្បាប់ ការទប់ស្កាត់ការទន្រ្ទានដីព្រៃខុសច្បាប់ ខណៈយកចិត្តទុកដាក់លើការអភិវឌ្ឍរបរចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន និងការអនុវត្តកម្មវិធីផ្សេងៗទៀតដើម្បីលើកទឹកចិត្ត និងកៀរគរការចូលរួមរបស់ប្រជាជនមូលដ្ឋានក្នុងការអភិរក្សធនធានធម្មជាតិ និងអភិវឌ្ឍន៍ជីវភាពប្រកបដោយនិរន្តរភាព។

ទីភ្នាក់ងារជំនួយអាមេរិក (USAID) បានគាំទ្រការតាមដានសត្វក្រចកជើងជំពាមដោយប្រើវិធីសាស្រ្តដើរបន្ទាត់ត្រង់ (line-transect) ពីឆ្នាំ២០១៨-២០២០។ យើងសូមថ្លែងអំណរគុណផងដែរដល់សមាជិកក្រុមស្រាវជ្រាវនិងតាមដានជីវៈចម្រុះទាំងអស់ ក៏ដូចជាក្រុមសហនិពន្ធនៃរបាយការណ៍ស្តីពីស្ថានភាពសត្វក្រចកជើងចំពាម ក៏ដូចជាអ្នករួមចំណែកទាំងអស់ក្នុងសកម្មភាពស្រាវជ្រាវទាំងអស់នេះ។

ក្រសួងបរិស្ថានសូមអំពាវនាវដល់សាធារណជនទូទៅ សូមបញ្ឈប់ការបរិភោគសាច់សត្វព្រៃនិងបញ្ឈប់ការប្រើប្រាស់ផលិតផលសត្វព្រៃគ្រប់ប្រភេទ។

**ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋលេខាធិការក្រសួងបរិស្ថានមានបន្ថែមថា "យើងខ្ញុំសូមស្នើយ៉ាងទទួចដល់ប្រជាជនទាំងអស់នៅទូទាំងប្រទេសកម្ពុជា សូមនិយាយថា "**ទេ**" ចំពោះសាច់សត្វព្រៃ ហើយសូមចូលរួមក្នុងការការពារនិងអភិរក្សធនធានធម្មជាតិរបស់កម្ពុជាឱ្យស្ថិតនៅគង់វង្សដើម្បីជាប្រយោជន៍ដល់មនុស្សជំនាន់ក្រោយៗទៀត។"

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
ឯកឧត្តម **នេត្រ ភក្ត្រា** រដ្ឋលេខាធិការនិងជាមន្រ្តីនាំពាក្យក្រសួងបរិស្ថាន
ទូរស័ព្ទ៖ ០១២ ៤៨៣ ២៨៣

លោក **ទេព អស្នារិទ្ធ** ប្រធានកិច្ចការសាធារណៈ និងគ្រប់គ្រងព័ត៌មាននៃអង្គការ WWF-កម្ពុជា
អ៊ីម៉ែល៖ asnarith.tep@wwf.org.kh ទូរស័ព្ទ៖ ០១២ ៩៥៧ ៩១៩

តំណភ្ជាប់ទៅកាន់រូបភាព និងឯកសារសំខាន់ៗ